ព្រឹកព្រលឹម ពន្លឺនៃក្ដីសង្ឃឹម បានជះពីលើជីវិតមនុស្ស។ ខ្ញុំក៏បានរៀបចំខ្លួន ដើម្បីទៅធ្វើកិច្ចការមួយដែលខ្ញុំគិតថា ត្រឹមត្រូវ និងយុត្តិធម៌សម្រាប់មនុស្សគ្រប់គ្នា។ ខ្ញុំឈរនៅមុខកញ្ចក់ ញញឹមជាមួយនឹងការសម្រេចចិត្តរបស់ខ្លួនឯង។

ខ្ញុំមកដល់ប៉ុស្ដិ៍នគរបាលក្បែរផ្ទះ ដែលខ្ញុំជិះកាត់រាល់ព្រឹក ប៉ុន្តែមិនធ្លាប់ចូលម្ដងណាទេ។ នេះជាលើកទីមួយរបស់ខ្ញុំដែលបង្ហាញខ្លួននៅទីនេះ ហើយបើខ្ញុំគិតមិនខុសទេ នេះក៏ជាលើកចុងក្រោយរបស់ខ្ញុំដែរ។

ខ្ញុំដើរចូលទៅ ហើយនិយាយយ៉ាងគួរសម "អត់ទោស ពូ ខ្ញុំមានរឿងចង់ប្ដឹង"។ ខ្ញុំនឹកឃើញថានិយាយខុសក៏និយាយម្ដងទៀតភ្លាម "មិនមែនប្ដឹងទេ គឺសារភាព"។ គ្រប់គ្នាដែលនៅក្នុងបន្ទប់នោះ មើលមកខ្ញុំ ហើយមើលមុខគ្នាទៅវិញទៅមក ហាក់ដូចជាមិនយល់ពីអ្វីដែលខ្ញុំកំពុងនិយាយ។ ដោយយល់ការល្អ ខ្ញុំក៏និយាយម្ដងទៀត "ខ្ញុំបានធ្វើរឿងមួយដែលខ្ញុំគិតថា ប្រហែលជាខុសច្បាប់"។

ពូប៉ូលីសម្នាក់ដើរមករកខ្ញុំ ហើយនិយាយថា "បើមានរឿងអី ចូលបន្ទប់ពូ ហើយចាំនិយាយ"។ ខ្ញុំក៏ដើរតាមគាត់។ ខ្ញុំគិតថាគាត់ប្រហែលជាមេប៉ូលីសនៅទីនេះហើយ។ គាត់ដើរលឿនពេក ខ្ញុំមើលស្លាកឈ្មោះនៅជាប់អាវរបស់គាត់មិនទាន់។

"តោះ! មានរឿងអីចង់និយាយ និយាយចេញមក ពូចាំស្ដាប់។ បើសិនជាគ្មានរឿងអីធំដុំទេ ចាំពូដេញអាអូនឯងទៅផ្ទះវិញ។"

"ប្រហែលមិនបានដេញទេពូ។" ខ្ញុំតបព្រមជាមួយនឹងស្នាមញញឹមទៅកាន់គាត់។

ខ្ញុំដកដង្ហើមចូលមួយសិន ហើយព្យាយាមប្រមូលយករឿងដែលកើតឡើងទាំងប៉ុន្មានមកទុកក្នុងខួរក្បាលខ្លួនឯង មុននឹងបញ្ចូលទៅកាន់ពូប៉ូលីស។

"ខ្ញុំឈ្មោះ បិន វិច្ឆ័យ។ ឆ្នាំនេះ អាយុ ២២ឆ្នាំ។ ខ្ញុំធ្វើការផ្នែករដ្ឋបាល ក្នុងក្រុមហ៊ុនតូចមួយ។ កាលពីប៉ុន្មានខែមុន ខ្ញុំបានលួចស្រលាញ់ស្រីម្នាក់ដែលធ្វើការនៅ

ក្រុមហ៊ុនជាមួយគ្នា។ ខ្ញុំមិនបានប្រាប់គេទេ ព្រោះមិនហ៊ាន ហើយណាមួយខ្លាចគេដឹងហើយទៅ គេឈប់និយាយជាមួយខ្ញុំ។”

ពូប៉ូលីស ធ្វើមុខដូចភ្ញាក់ផ្អើលនៅពេលស្តាប់ខ្ញុំនិយាយរឿងនេះ។ គាត់ប្រហែលជាគិតថា ខ្ញុំយកបញ្ហាស្នេហាមកប្តឹងដល់ប៉ុស្តិ៍ហើយមើលទៅ។ ខ្ញុំក៏បន្ត កុំឲ្យគាត់ដាច់សាច់រឿង។

“ក្រោយមក ខ្ញុំបានប្តូរក្រុមទៅធ្វើការជាមួយនាង ហើយក៏ចាប់ផ្តើមស្គាល់នាង។ ដោយសារការងារក្រុមហ៊ុន ហេតុនេះពេលខ្លះពួកយើងត្រូវជជែកគ្នាតាមឆាត ពេលត្រលប់មកផ្ទះ។ ការធ្វើការងារជាមួយគ្នា ធ្វើឲ្យខ្ញុំបានស្គាល់នាងជិតដិតជាងមុន តែខ្ញុំក៏មិនប្រាប់នាងពីរឿងលួចស្រលាញ់ដែរ។ ខ្ញុំព្យាយាមលាក់ទៀតផង។”

“បានប្រហែលជាមួយខែក្រោយការស្គាល់គ្នានេះ ពួកយើងចាប់ផ្តើមនិយាយរឿងផ្ទាល់ខ្លួនទៅវិញទៅមក ព្រោះនាងហាក់ដូចជាទុកខ្ញុំជាមិត្តភក្តិរបស់នាងទៅហើយ។ នាងនិយាយថា សំណាងណាស់ ដែលមានខ្ញុំចាំស្តាប់នាងនិយាយ ព្រោះអ្នកដទៃមិនរវល់ពីនាងទេ។ ខ្ញុំចាប់ផ្តើមអានិតនាងបន្តិចម្តង ប៉ុន្តែក៏ចូលចិត្តរឿងដែលនាងនិយាយប្រាប់ខ្ញុំដែរ។”

“ថ្ងៃមួយ នាងនិយាយដល់បញ្ហាស្នេហារបស់នាង។ ពេលនោះខ្ញុំហាក់ដូចជាអន់ចិត្តបន្តិច ព្រោះកន្លងមក ខ្ញុំមិនបានដឹងថានាងស្នេហានោះទេ។ ប្រហែលមកពីខ្ញុំមិនដែលសួរ ទើបនាងមិនប្រាប់។ អ្នកដែលនាងស្រលាញ់ ក៏ធ្វើការក្នុងក្រុមហ៊ុនជាមួយខ្ញុំដែរ ប៉ុន្តែនៅផ្នែកផ្សេង ហេតុនេះទើបខ្ញុំមិនសូវចាប់អារម្មណ៍។”

ខ្ញុំឈប់មួយស្របក់ ដើម្បីសម្រាកមាត់បន្តិច និងដើម្បីមើលពូប៉ូលីសផង។ គាត់សម្លឹងមុខខ្ញុំ ធ្វើដូចធម្មតា ហើយក៏និយាយថា “និយាយតទៅ ពូកំពុងតែស្តាប់”។ ខ្ញុំបម្រុងនឹងនិយាយបន្ត ស្រាប់តែទ្វារបន្ទប់របស់គាត់របើកឡើង ហើយលេចមុខប៉ូលីសពីរនាក់ដើរចូលមក។

“អូ! បងកំពុងមានភ្ញៀវ ចាំនិយាយពេលក្រោយក៏បានដែរ” ប៉ូលីសដែលកំពុងកាន់ក្រដាសមួយដុំធំ និយាយនៅពេលក្រឡេកឃើញខ្ញុំ។ ចំណែកប៉ូលីសម្នាក់ទៀតបានទាញដៃគាត់ចេញ ប៉ុន្តែត្រូវមេប៉ូលីសឃាត់។

“ចូលមកអង្គុយស្តាប់សិនមក អាអូននេះមានរឿងចង់សារភាព” គាត់ចង្អុលកៅអីក្បែរជញ្ជាំង ហើយប៉ូលីសទាំងពីរនាក់ក៏អង្គុយតាមការបញ្ជា។

“និយាយតទៅ អាអូន”

“បាទ។ រាល់ដងពេលដែលនាងនិយាយពីបញ្ហាជាមួយសង្សាររបស់នាង ខ្ញុំតែងតែស្តាប់ដោយប្រុងប្រយ័ត្នបំផុត ព្រោះពេលនិយាយចប់ នាងតែងតែសួរយោបល់របស់ខ្ញុំ។ ពីដំបូងៗ ខ្ញុំមិនសូវជាចង់និយាយរឿងនេះទេ ប៉ុន្តែក្រោយពេលខ្ញុំស្តាប់យូរទៅ ខ្ញុំមានអារម្មណ៍ថា ចូលចិត្តស្តាប់បញ្ហារបស់នាង។ ខ្ញុំតែងតែចង់ដឹងបន្ថែមពីអ្វីដែលកើតឡើងក្នុងជីវិតរបស់នាងជានិច្ច។ មុនពេលយើងបិទទូរស័ព្ទ នាងតែងតែអរគុណខ្ញុំដែលបានជួយស្តាប់នាងនិយាយ។”

“ប៉ុន្មានថ្ងៃក្រោយមក នាងបានណែនាំខ្ញុំឲ្យស្គាល់សង្សាររបស់នាង តែនាងផ្តាំថា កុំថានាងឆាតលេងជាមួយខ្ញុំរាល់យប់ ព្រោះនាងមិនចង់ឲ្យមានការយល់ច្រឡំ។ ខ្ញុំយល់ និងឯកភាពមួយរយភាគរយ។ ខ្ញុំធ្វើធម្មតា ទោះបីជាពិបាកទ្រាំពេលឃើញពួកគេស្និទ្ធស្នាលនឹងគ្នាក៏ដោយ។”

“ចាប់តាំងពីពេលនោះមក នាងមិនសូវបានទាក់ទងមកខ្ញុំទៀតទេ។ ខ្ញុំគិតថាប្រហែលជា នាងត្រូវគ្នាជាមួយសង្សារនាងវិញហើយ ទើបគ្មានពេលរវល់ជាមួយខ្ញុំ។ ខ្ញុំមិនសូវជានឹកនាងប៉ុន្មានទេ បើនិយាយឲ្យត្រង់ទៅ ប៉ុន្តែខ្ញុំនឹករឿងដែលនាងធ្លាប់យកប្រាប់ខ្ញុំ។ ខ្ញុំមានអារម្មណ៍ថា ជក់នឹងរឿងទាំងនោះជាង។ ខ្ញុំមិនហ៊ានសួរនាងពេលជួបមុខគ្នានៅកន្លែងធ្វើការ។ ទោះបីសួរ ក៏មិនដឹងសួរថាម៉េចដែរ ព្រោះខ្ញុំគ្មានត្រូវអ្វីជាមួយនាងផង។”

“ខ្ញុំនៅមិនសុខប៉ុន្មានសប្ដាហ៍ ព្រោះនាងមិនមានប្រាប់អ្វីទាំងអស់។ នាងគ្មានបញ្ហា ខ្ញុំគួរតែសប្បាយចិត្តជំនួសនាង តែវាមិនអីចឹងទេ ខ្ញុំបែរចង់ឲ្យនាងមានបញ្ហាទៅវិញ។ ខ្ញុំក៏កើតគំនិតមួយ។ ខ្ញុំគិតថា បើសិនជានាងបញ្ហាកាន់តែធំជាងមុន នាងនឹងមានរឿងនិយាយជាមួយខ្ញុំកាន់តែច្រើន ហើយខ្ញុំក៏មិនបាច់អផ្សុក មិនដឹងធ្វើអ្វីដែរ។ គិតទៅគិតមក ខ្ញុំក៏នឹកឃើញវិធីមួយ។”

ពូប៉ូលីសពីរនាក់ទៀត សម្រួលឥរិយាបថ ហាក់ដូចជាដឹងថា កន្លែងល្អក្នុងរឿងជិតដល់ហើយ។ ពូមេប៉ូលីស អង្គុយជម្មតា ប៉ុន្តែគាត់ជ្រួញចិញ្ចើមដោយសារការចង់ដឹងបន្តិច។

“កាលពីចុងខែមុននេះ ក្រុមហ៊ុនរបស់ខ្ញុំមានកម្មវិធីជប់លៀងមួយ។ បុគ្គលិកទាំងអស់សប្បាយណាស់ ផឹកស្រវឹងគ្រប់គ្នា។ គេចាក់ភ្លេងលឺទ្រហឹងពេញបន្ទប់ធ្វើការ។ ខ្ញុំមិនបានផឹកនឹងគេទេ ព្រោះខ្ញុំមានរឿងផ្សេងដែលត្រូវធ្វើនៅយប់នោះ។ ខ្ញុំសម្លឹងមើលសង្សាររបស់នាងរហូត។ មួយសន្ទុះ គេក៏ងើបឡើងទ្រេតទ្រោត។ ខ្ញុំគិតថាគេច្បាស់ជារាន់នោមហើយ ដូច្នេះខ្ញុំក៏ងើបដើរទៅបន្ទប់ទឹកមុនគេ។”

“បន្ទប់ទឹកស្ងាត់ណាស់ គ្មានអ្នកណានៅក្នុងនោះទេ។ ខ្ញុំដកស្បោងប្លាស្ទិកដែលខ្ញុំយកមកពីផ្ទះ កាន់ជាប់នឹងដៃ។ ខ្ញុំឈរចាំសង្សារនាងនៅក្នុងនោះមួយសន្ទុះ ក៏លឺសូរជើងមនុស្សដើរចូលមក។ ដោយសារតែស្រវឹង គេមិនបានមើលអ្វីច្រើនទេ ក៏រុញទ្វារហើយ ឈរនោមតែម្ដង។ គេមិនចាក់សោរ ខ្ញុំក៏ដើរទៅពីក្រោយ យកថង់នោះស៊កពីលើក្បាលគេ។ ខ្ញុំក្រប្ដួចមាត់ស្បោង ជាប់នឹងកគេ ហើយធាក់គន្លាក់ជើងគេពីក្រោយមួយទំហឹង។ គេទន់ជើងចុះ ហើយប្រឹងរើបម្រះ ប៉ុន្តែដោយសារគេស្រវឹង កម្លាំងរបស់គេ មិនឈ្នះខ្ញុំទេ។”

ពូមេប៉ូលីស ចាប់ផ្ដើមងើបខ្លួនអង្គុយត្រង់ នៅពេលខ្ញុំនិយាយដល់ត្រង់នេះ។ ខ្ញុំមិនបានងាកមើលប៉ូលីសដែលអង្គុយក្រោយខ្ញុំទេ ប៉ុន្តែខ្ញុំជឿថា ពួកគាត់ក៏ភ្ញាក់ផ្អើលដូចគ្នាដែរ។ ខ្ញុំក៏បន្តរឿងរបស់ខ្ញុំទៀត។

“ខ្ញុំចាប់ស្បោងជាប់ មិនឲ្យគេដកដង្ហើមរួច ហើយខ្ញុំយកកែងដៃរបស់ខ្ញុំ សង្កត់ក្បាលគេចុះក្រោម។ គេបញ្ចេញសម្លេងគ្រលរៗ ប៉ុន្តែមិនអាចឈ្នះសម្លេងភ្លេងដែលនៅខាងក្រៅទេ។ ខ្ញុំបិទភ្នែកចាំមួយសន្ទុះធំ រហូតគេឈប់រើ ទើបខ្ញុំព្រលែងដៃ។ ខ្ញុំលូកស្ទាបដង្ហើមរបស់គេ ខ្ញុំគិតថាគេស្លាប់ហើយ ដូច្នេះខ្ញុំក៏យកស្បោងនោះបោះចូលក្នុងបង្គន់ ហើយចុចទឹក។ ខ្ញុំទាញទ្វារបង្គន់បិទវិញ ហើយលាងដៃដើរទៅចូលរួមជាមួយបុគ្គលិកដទៃទៀត។”

“ដោយសារខ្ញុំធ្វើកិច្ចការបានជោគជ័យហើយ ខ្ញុំក៏ចាប់ផ្តើមផឹកបៀរជាមួយគេឯងដែរ។ ក្រោយមកខ្ញុំក៏ស្រវឹង ដេកលក់នៅនឹងតុផឹកនោះទៅ។ ខ្ញុំភ្ញាក់ឡើងមកវិញនៅពេលលឺសម្លេងស្រែកយំរបស់ស្រីម្នាក់។ ខ្ញុំបើកភ្នែកសន្សឹមៗឡើង ហើយមើលទៅលើដី។ សាកសពសង្សារនាង កំពុងដេកស្តូកស្តឹក ហើយអ្នកដទៃទៀត បានត្រឹមតែឈរមើល ព្រោះធ្វើអ្វីមិនកើត។ បុគ្គលិកស្រីៗខ្លះយំតាមនាងដែរ។”

“ខ្ញុំធ្វើជាសួរម្នាក់ដែលឈរជិតខ្ញុំថាមានរឿងអីកើតឡើង? គេប្រាប់ខ្ញុំថា ឃើញគាត់ដេកស្លាប់លើចានបន្តន់ សង្ស័យតែខ្យល់គរស្លាប់។ ខ្ញុំមិននិយាយអ្វីបន្ត បានត្រឹមតែឈរមើលនាងយំ។”

ពូមេប៉ូលីស លើកដៃឃាត់ ហើយសួរខ្ញុំថា “ឯងសម្លាប់គេក្នុងបន្ទប់ទឹកក្រុមហ៊ុន?”

“បាទ ខ្ញុំជាអ្នកសម្លាប់”

“ហើយហេតុអីបានជាសម្លាប់គេ? ខឹងគេស្រលាញ់ស្រីជាមួយឯងមែន?”

“អត់ទេ។ ខ្ញុំចង់ឲ្យនាងមានបញ្ហា ហើយមករកខ្ញុំនិយាយគ្នាទៀត។ ខ្ញុំចូលចិត្តស្តាប់បញ្ហារបស់នាង។”

“ឯងឆ្កួត ឬក៏យ៉ាងម៉េច?”

“ខ្ញុំមិនឆ្កួតទេ គ្រាន់តែខ្ញុំចូលចិត្តស្តាប់បញ្ហារបស់អ្នកដទៃប៉ុណ្ណោះ។ វាដូចតែពូចូលចិត្តតាមដានរឿងភាគអ៊ីចឹង។ ស្រីដែលខ្ញុំស្រលាញ់ ក្លាយជាតួអង្គដែលខ្ញុំចូលចិត្ត អ៊ីចឹង ខ្ញុំចង់ឲ្យនាងជួបបញ្ហាថែមទៀត ទើបល្អមើល។”

ពូមេប៉ូលីស ស៊ីញ៉េភ្នែកដាក់គ្នីគ្នាគាត់ដែលឈរពីក្រោយខ្ញុំ។ ពួកគាត់ក៏មកទាញដៃខ្ញុំទៅខាងក្រោយ ចង់វាយខ្នោះខ្ញុំ។

“ខ្ញុំមកសារភាពដល់ប៉ុស្តិ៍ប៉ូលីសហើយ ពូមិនបាច់ប្រើដៃខ្លាំងពេកទេ។”

ខ្ញុំរើបម្រះ ក៏លូកដៃទៅប៉ះកាំភ្លើងដែលសៀតជាប់នៅចង្កេះគាត់។ ដោយសារខ្ញុំមានមាឌធំ ហេតុនេះខ្ញុំអាចរុញប៉ូលីសទាំងពីរដែលនៅក្រោយខ្ញុំឲ្យខ្ទាតចេញបាន។ ពូមេប៉ូលីស ឃើញមិនស្រួល ក៏ដកកាំភ្លើងរបស់គាត់ចេញមកដែរ ហើយភ្ជង់ខ្ញុំ។ ខ្ញុំក៏កំពុងភ្ជង់គាត់ដូចគ្នាដែរ។

“កុំធ្វើអីផ្តេសផ្តាស អាអូន! យើងនិយាយគ្នាបាន។”

“ពូដាក់កាំភ្លើងចុះមុនទៅ ចាំខ្ញុំដាក់តាមក្រោយ។”

ពូមេប៉ូលីស លើកដៃឃាត់កូនចៅរបស់គាត់ មិនឲ្យធ្វើសកម្មភាព។ គាត់ក៏ដាក់កាំភ្លើងចុះសន្សឹមៗ នៅលើតុរបស់គាត់។ ខ្ញុំក៏កេះកៃកាំភ្លើងក្នុងដៃរបស់ខ្ញុំ ហើយយកមកដាក់ជាប់ចង្ការរបស់ខ្ញុំ។

“ហេ! កុំ! កុំ! ដាក់កាំភ្លើងចុះទៅ”

“ខ្ញុំចង់តែសារភាពទេ អត់បានថាចង់ជាប់គុកទេ។ អរគុណពូដែលបានស្តាប់រឿងខ្ញុំ។”

ប៉ូលីសដែលនៅក្រោយខ្នងខ្ញុំរត់មក បម្រុងនឹងចាប់ខ្ញុំ តែម្រាមដៃខ្ញុំនៅជាប់កាំភ្លើងស្រាប់ ហេតុនេះពួកគេគ្មានសំណាងឃាត់ទាន់ទេ។

ផាំង! សម្លេងកាំភ្លើង លឺលាន់ពេញ ត្រជាក់របស់ខ្ញុំ មុននឹងខ្ញុំដួលទៅលើដៃ។ ខ្ញុំមើលលែងឃើញអ្វីទាំងអស់ ក្រៅពីពន្លឺពណ៌ស។

ខ្ញុំបើកភ្នែកឡើងវិញ ឃើញខ្លួនឯងកំពុងតែដេកលើគ្រែក្នុងបន្ទប់។ ខ្ញុំបែកញើសជោគថ្ងាស ក្រឡេកមើលឆ្វេងស្តាំ គ្មានឃើញប៉ូលីសណាសោះ។ ខ្ញុំយកដៃស្ទាបចង្កេះខ្លួនឯង ក៏គ្មានស្នាមរបួសអ្វីដែរ។

តាមពិត ខ្ញុំយល់សប្តិសោះ។

ខ្ញុំងើបចេញពីគ្រែ ដើរចេញពីបន្ទប់ ដោយហួសចិត្តនឹងការយល់សប្តិនោះ។ ពេលចុះមកដល់ក្រោម ម៉ាក់ខ្ញុំរបស់ខ្ញុំក៏ប្រាប់ថា “ថ្ងៃបន្តិច ជួយជូនម៉ាក់ទៅយកសំពត់សិនចាំកូនហួសទៅបុណ្យសពអ្នកធ្វើការជាមួយកូនចុះ។”

“បុណ្យសពអ្នកណា ម៉ាក់?”

“ម៉ាក់មិនស្គាល់ទេ។ កូនប្រាប់ថា គេខ្យល់គរស្លាប់ពេលជប់លៀងនៅក្រុមហ៊ុន។”

ខ្ញុំឈរស្ងៀម ព្រោះកំពុងតែវង្វេង។

តើការយល់សប្តិរបស់ខ្ញុំ ក្លាយជាការពិត ឬការពិត ក្លាយជាការយល់សប្តិ។ តើខ្ញុំពិតជាសម្លាប់គេមែនឬ? ហើយតើខ្ញុំគួរតែទៅសារភាពទោសដែរទេ?